# ធម្មជាតិនៃភាពជាសិស្ស

សុិលវីយ៉ា អេជ អាល់រ៉េដ
ទីប្រឹក្សាទីមួយក្នុង គណៈប្រធានសមាគមសង្គ្រោះទូទៅ

*នៅពេលក្ដីស្រឡាញ់ក្លាយទៅជាគោលការណ៍ណែនាំនៅក្នុងការថែទាំរបស់យើងចំពោះអ្នកដទៃ នោះការបម្រើរបស់យើងចំពោះពួកគេក្លាយទៅជាគំរូក្នុងការរស់នៅតាមដំណឹងល្អ ។*

ចាប់តាំងពីដើមដំបូងមក ព្រះអម្ចាស់បានបង្រៀនថា ដើម្បីក្លាយជារាស្ត្រទ្រង់ យើងត្រូវមានចិត្តតែមួយ និងគំនិតតែមួយ ។[1] ព្រះអង្គសង្គ្រោះបានពន្យល់ផងដែរថា បទបញ្ញត្តិដ៏ធំពីរគឺ « ត្រូវឲ្យស្រឡាញ់ព្រះអម្ចាស់ ជាព្រះនៃឯងឲ្យអស់អំពីចិត្ត អស់ពីព្រលឹង ហើយអស់ពីគំនិតឯង » និង « ត្រូវឲ្យស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង » ។[2] នៅទីបំផុត បន្ទាប់ពីសាសនាចក្រត្រូវបានស្ដារឡើងវិញបានមិនយូរប៉ុន្មាន ព្រះអម្ចាស់បានបញ្ជាពួកបរិសុទ្ធឲ្យ « សួរសុខទុក្ខដល់មនុស្សទ័លក្រ និងមនុស្សកម្សត់ទុរគត ហើយជួយឧបត្ថម្ភដល់ការរំដោះពួកគេផង » ។[3]

តើអ្វីជាខ្លឹមសាររួមនៅក្នុងបទបញ្ញត្តិទាំងនេះ ? នោះគឺថា យើងត្រូវតែស្រឡាញ់ ហើយបម្រើគ្នាទៅវិញទៅមក ។ នេះគឺជាភាពពិតនៃធម្មជាតិនៃភាពជាសិស្សនៅក្នុងសាសនាចក្រដ៏ពិតនៃព្រះយេស៊ូវគ្រីស្ទ ។

នៅពេលយើងប្រារព្ធខួបលើកទី 75 នៃកម្មវិធីសុខុមាលភាពរបស់សាសនាចក្រ យើងត្រូវបានរលឹកពីគោលបំណងទាំងឡាយនៃសុខុមាលភាព គឺត្រូវជួយសមាជិកឲ្យជួយខ្លួនគេ ឲ្យក្លាយជាមានការពឹងផ្អែកលើខ្លួនឯង ខ្វល់ខ្វាយចំពោះអ្នកទ័លក្រ និងអ្នកកម្សត់ទុរគត ហើយផ្ដល់ការបម្រើ ។ សាសនាចក្របានរៀបចំធនធានទាំងឡាយ ដើម្បីជួយដល់សមាជិកក្នុងការផ្ដល់ដល់សុខុមាលភាពខាងសាច់ឈាម ខាងវិញ្ញាណ ខាងសង្គម និងខាងផ្លូវចិត្តរបស់ពួកគេ ក្រុមគ្រួសារគេ និងអ្នកដទៃទៀត ។ ការិយាល័យរបស់ប៊ីស្សពមានតួនាទីដ៏ពិសេសក្នុងការថែទាំអ្នកទ័លក្រ និងផ្ដល់ធនធានទាំងនោះដល់សមាជិកក្នុងវួដរបស់គាត់ ។ ក្នុងការខិតខំរបស់គាត់ គាត់បានជំនួយពីកូរ៉ុមបព្វជិតភាព សមាគមសង្គ្រោះ និងគ្រូបង្រៀន និងគ្រូសួរសុខទុក្ខតាមផ្ទះ ។

សមាគមសង្គ្រោះគឺតែងតែជាផ្នែកដ៏សំខាន់បំផុតនៃសុខុមាលភាព ។ នៅពេលព្យាការី យ៉ូសែប ស្ម៊ីធ បានរៀបចំសមាគមសង្គ្រោះឡើងក្នុងឆ្នាំ 1842 គាត់បានមានប្រសាសន៍ទៅកាន់បងប្អូនស្ត្រីថា « នេះជាការចាប់ផ្ដើមនៃថ្ងៃល្អចំពោះអ្នកទ័លក្រ និងកម្សត់ទុរគត » ។ គាត់បានប្រាប់បងប្អូនស្ត្រីថា គោលបំណងនៃសមាគមសង្គ្រោះគឺ រំដោះអ្នកទ័លក្រ ទុរគត ស្ត្រីមេម៉ាយ និងក្មេងកំព្រា និងដើម្បីអនុវត្តអស់ទាំងគោលបំណងដ៏សន្ដោសប្រណី... ។

ពួកគេនឹងចាក់ប្រេង និងស្រា លាបដួងចិត្តដែលមានរបួស និងទុក្ខព្រួយ ពួកគេនឹងជូតទឹកភ្នែកក្មេងកំព្រា និងធ្វើឲ្យដួងចិត្តស្ត្រីមេម៉ាយបានរីករាយ » ។[4]

គាត់ក៏បានថ្លែងផងដែរថា សមាគម « អាចបណ្ដាលចិត្តឲ្យបងប្អូនប្រុសធ្វើការល្អ ក្នុងការមើលថែតម្រូវការរបស់អ្នកទ័លក្រ ស្វែងរកមើលអ្នកដែលត្រូវការជំនួយសប្បុរសធម៌ និងផ្ដល់តាមតម្រូវការរបស់ពួកគេ ដើម្បីជួយដោយការកែតម្រូវផ្នែកសីលធម៌ និងពង្រឹងគុណធម៌នៃសហគមន៍ » ។[5] បុរសស្ត្រីនៃសាសនាចក្រ ចូលរួមជាមួយគ្នាថ្ងៃនេះ នៅក្នុងការរំដោះដល់ពួកអ្នកដែលត្រូវការជំនួយនោះ ។ អ្នកកាន់បព្វជិតភាពផ្ដល់នូវការគាំទ្រចាំបាច់ដល់ពួកអ្នកដែលត្រូវការការណែនាំខាងវិញ្ញាណ និងជំនួយ ។ គ្រូបង្រៀនតាមផ្ទះដែលពេញដោយការបំផុសគំនិត ផ្ដល់ពរជ័យដល់ជីវិតមនុស្សជាច្រើន និងផ្ដល់ពរជ័យនៃដំណឹងល្អដល់គ្រប់គ្រួសារ ។ ជាងនោះទៅទៀត ពួកគេចែកចាយកម្លាំង និងជំនាញរបស់ពួកគេ នៅក្នុងរបៀបផ្សេងៗ ដូចជាជួយដល់គ្រួសារក្នុងការជួសជុលផ្ទះ រើផ្ទះ ឬជួយដល់បងប្រុសម្នាក់រកការងារធ្វើ ។

ប្រធានសមាគមសង្គ្រោះទៅសួរសុខទុក្ខតាមផ្ទះដើម្បីប៉ាន់ប្រមាណពីតម្រូវការផ្សេងៗ ជំនួសឲ្យប៊ីស្សព ។ គ្រូបង្រៀនសួរសុខទុក្ខដែលពេញដោយការបំផុសគំនិត មើលថែបងប្អូនស្ត្រី និងគ្រួសារ ។ ជាញឹកញាប់ពួកគេគឺជាអ្នកឆ្លើយតបទាន់តម្រូវការ ។ បងប្អូនស្ត្រីនៃសមាគមសង្គ្រោះផ្ដល់អាហារ ការបម្រើដ៏ករុណា និងការគាំទ្រជានិច្ចក្នុងពេលនៃការលំបាក ។

សមាជិកសាសនាចក្រទាំងអស់ទូទាំងពិភពលោក បានត្រេកអរក្នុងអតីតកាល ហើយគួរតែត្រេកអរឥឡូវនេះ ចំពោះឱកាសដែលយើងបានបម្រើអ្នកដទៃ ។ ការខិតខំប្រឹងប្រែងរួមគ្នារបស់យើងនាំមកនូវការរំដោះដល់ពួកអ្នកទ័លក្រ អ្នកស្រេកឃ្លាន រងទុក្ខ ឬមានទុក្ខព្រួយ ដែលជាការសង្គ្រោះដល់ព្រលឹងទាំងឡាយ ។

គ្រប់បីស្សពមានឃ្លាំងរបស់ព្រះ ដែលបានស្ថាបនាឡើងដោយសមាជិកដ៏ស្មោះត្រង់ ដោយផ្ដល់ឲ្យបីស្សពនូវពេលវេលា ទេពកោសល្យ ជំនាញ សេចក្ដីមេត្តា សម្ភារៈ និងទ្រព្យ របស់ពួកគេ ដើម្បីថែរក្សាអ្នកទ័លក្រ និងនៅក្នុងការកសាងនគរនៃព្រះលើផែនដី ។[6] យើងទាំងអស់គ្នាអាចបរិច្ចាគដល់ឃ្លាំងរបស់ព្រះ នៅពេលយើងបង់ដង្វាយតមអាហារ និងធ្វើយ៉ាងណាឲ្យបីស្សពអាចប្រើធនធានទាំងអស់របស់អ្នក ដើម្បីជួយដល់ពួកអ្នកដែលត្រូវការ ។

ថ្វីបើពិភពលោកនេះផ្លាស់ប្ដូរយ៉ាងឆាប់រហ័សក្ដី ក៏គោលការណ៍សុខុមាលភាពមិនបានផ្លាស់ប្ដូរតាមពេលវេលានោះទេ ព្រោះគោលការណ៍ទាំងនោះត្រូវបានបំផុសដោយព្រះ ជាសេចក្ដីពិតដែលបានបើកបង្ហាញ ។ ពេលសមាជិកសាសនាចក្រ និងគ្រួសាររបស់គេ ធ្វើអ្វីៗទាំងអស់ដែលគេអាច ដើម្បីទ្រទ្រង់ខ្លួនគេ ហើយនៅតែមិនអាចគ្រប់តាមតម្រូវការចាំបាច់ នោះសាសនាចក្រត្រៀមរួចជាស្រេចដើម្បីជួយ ។

តម្រូវការរយៈពេលខ្លីត្រូវបានបំពេញភ្លាមៗ ហើយផែនការមួយដើម្បីជួយអ្នកទទួលផលឲ្យក្លាយជាមានការពឹងផ្អែកលើខ្លួនឯងត្រូវបានបង្កើតឡើង ។ ការពឹងផ្អែកលើខ្លួនឯងគឺជាសមត្ថភាពក្នុងការផ្គត់ផ្គង់អ្វីដែលចាំបាច់ខាងវិញ្ញាណ និងសាច់ឈាមសម្រាប់ជីវិតខ្លួនឯង និងគ្រួសារ ។

ពេលយើងពង្រីកកម្រិតនៃការពឹងផ្អែកខ្លួនឯង យើងពង្រីកសមត្ថភាពយើងក្នុងការជួយ និងបម្រើដល់អ្នកដទៃ តាមរបៀបដែលព្រះអង្គសង្គ្រោះបានធ្វើ ។ យើងធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះ នៅពេលដែលយើងបម្រើដល់អ្នកដែលត្រូវការជំនួយ អ្នកឈឺ និងអ្នករងទុក្ខ ។ នៅពេលក្ដីស្រឡាញ់ក្លាយទៅជាគោលការណ៍ណែនាំនៅក្នុងការថែទាំរបស់យើងចំពោះអ្នកដទៃ នោះការបម្រើរបស់យើងចំពោះពួកគេក្លាយទៅជាគំរូក្នុងការរស់នៅតាមដំណឹងល្អ ។ វាគឺជាដំណឹងល្អនៅក្នុងគ្រាដ៏ល្អបំផុត ។ វាគឺជាសាសនាដែលបរិសុទ្ធ ។

ក្នុងការចាត់តាំងក្នុងសាសនាចក្រពីមុនរបស់ខ្ញុំ ខ្ញុំបានមានការបន្ទាបខ្លួន ដោយសារក្ដីស្រឡាញ់ និងការខ្វល់ខ្វាយដែលបីស្សព និងអ្នកដឹកនាំសមាគមសង្គ្រោះបង្ហាញដល់សមាជិករបស់ពួកគាត់ ។ ពេលខ្ញុំបម្រើជាប្រធានសមាគមសង្គ្រោះប្រចាំស្តេក នៅប្រទេស ឈីលី នៅដើមទសវត្សរ៍ឆ្នាំ 1980 ដែលប្រទេសនោះកំពុងជួបប្រទះបញ្ហាសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរ ហើយអត្រានៃការអត់ការងារធ្វើគឺ 30 ភាគរយ ។ ខ្ញុំបានធ្វើជាសាក្សីពីប្រធានសមាគមដ៏អង់អាចនិងគ្រូបង្រៀនសួរសុខទុក្ខដ៏ស្មោះត្រង់ ដែលបានបន្ត « ធ្វើល្អ » នៅក្នុងស្ថានភាពដ៏លំបាកនោះ ។ ពួកគេបានសម្ដែងចេញនូវបទគម្ពីរ សុភាសិត 31:20 « នាងឈោងដៃដល់មនុស្សកម្សត់ទុគ៌ត អើ នាងហុចដៃទៅជួយមនុស្សក្រលំបាកផង » ។

បងប្អូនស្រ្តីដែលគ្រួសារគាត់មានតែបន្តិចបន្តួចខ្លួនឯង បានជួយដល់អ្នកផ្សេងទៀតដែលគាត់គិតថាត្រូវការជំនួយជាងគាត់ ។ ពេលនោះ ខ្ញុំបានយល់កាន់តែច្បាស់ពីអ្វីដែលព្រះអង្គសង្គ្រោះបានឃើញ នៅពេលទ្រង់បានប្រកាសនៅក្នុង លូកា 21:3–4 ៖

« ខ្ញុំប្រាប់អ្នកជាប្រាកដថា ស្រីមេម៉ាយទ័លក្រនេះបានដាក់ដង្វាយលើសជាងគេទាំងអស់ ៖ ដ្បិតអ្នកទាំងនោះ សុទ្ធតែយកពីរបស់សំណល់ខ្លួនមកថ្វាយ តែឯស្ត្រីនេះ នាងបានយកពីសេចក្ដីកម្សត់របស់ខ្លួនមកថ្វាយវិញ គឺនាងបានថ្វាយរបស់ទាំងប៉ុន្មានដែលមានសម្រាប់នឹងចិញ្ចឹមជីវិតខ្លួនផង » ។

ពីរបីឆ្នាំក្រោមក ខ្ញុំបានឃើញការណ៍ដូចគ្នាដែរ ពេលជាប្រធានសមាគមសង្គ្រោះប្រចាំស្តេកក្នុងប្រទេស អាហ្សង់ទីន ពេលមានអតិផរណាយ៉ាងខ្លាំងក្នុងប្រទេសនេះ ហើយសេដ្ឋកិច្ចធ្លាក់ចុះ ដែលប៉ះពាល់ដល់សមាជិកដ៏ស្មោះត្រង់ជាច្រើនរបស់យើង ។ ប៉ុន្តែខ្ញុំបានឃើញម្ដងទៀត កំឡុងទស្សនកិច្ចថ្មីៗរបស់ខ្ញុំទៅកាន់ ទីក្រុង គីនហ្សាសា សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ ទីក្រុងអង់តាណាណារីវ៉ូ ប្រទេសម៉ាដាហ្គាស្កា និងទីក្រុងប៉ុលឡាវេយ៉ូ នៅប្រទេសហ្ស៊ីមបាវ៉េ ។ សមាជិករូបគ្រប់ទីកន្លែង ជាពិសេសបងប្អូនស្រ្តីនៃសមាគមសង្គ្រោះ បន្តកសាងសេចក្ដីជំនឿ ពង្រឹងបុគ្គល និងគ្រួសារទាំងឡាយ និងជួយដល់ពួកអ្នកដែលត្រូវការជំនួយ ។

មិនគួរឲ្យជឿទេ ក្នុងការគិតថាបងប្អូនប្រុសស្រីដ៏រាបទាបទាំងនោះ ជាមួយនឹងការហៅបម្រើក្នុងសាសនាចក្រ អាចទៅកាន់ផ្ទះមួយដែលមានភាពក្រីក្រ ទុក្ខព្រួយ ជំងឺ ឬការឈឺចាប់ ហើយអាចនាំនូវក្ដីសុខសាន្ត ការសោយចិត្ត និងសុភមង្គលចូលក្នុងផ្ទះនោះ ។ មិនថាវួដ ឬសាខានោះនៅទីណា ឬធំ ឬតូចយ៉ាងណានោះទេ សមាជិកគ្រប់រូបនៅទូទាំងពិភពលោកមានឱកាសធ្វើដូច្នោះ ។ វាកើតឡើងជារៀងរាល់ថ្ងៃ ហើយវាកំពុងកើតឡើងនៅកន្លែងខ្លះនៅពេលឥឡូវនេះ ។ ខាឡា ជាម្ដាយវ័យក្មេងដែលមានកូនពីរនាក់ ។ ស្វាមីនាង ប្រេន ធ្វើការច្រើនម៉ោង ហើយធ្វើដំណើរមួយម៉ោងទៅធ្វើការ ។

ភ្លាមៗ បន្ទាប់ពីកំណើតកូនស្រីទីពីរ នាងបានមាននូវបទពិសោធន៍ដូចតទៅនេះ ។ « មួយថ្ងៃ បន្ទាប់ពីខ្ញុំបានទទួលការហៅជាទីប្រឹក្សាម្នាក់នៅក្នុងគណៈប្រធានសមាគមសង្គ្រោះប្រចាំវួដ ខ្ញុំបានចាប់ផ្ដើមមានអារម្មណ៍ថាជាបន្ទុកធ្ងន់ពេក ។ តើខ្ញុំអាចទទួលខុសត្រូវក្នុងការជួយថែរក្សាដល់ស្ត្រីក្នុងវួដយ៉ាងណាទៅ នៅពេលដែលខ្ញុំកំពុងមានបញ្ហា ក្នុងការបំពេញតួនាទីជាប្រពន្ធ និងម្ដាយនៃកូនអាយុពីរឆ្នាំដ៏រពឹស និងកូនដែលទើបនឹងកើតនោះ ? គ្រាន់តែពេលដែលមានអារម្មណ៍បែបនេះ កូនអាយុពីរឆ្នាំបានឈឺ ។ ខ្ញុំមិនប្រាកដទេថាត្រូវធ្វើអ្វីចំពោះកូនដែលឈឺ និងត្រូវថែទាំកូនតូចក្នុងពេលតែមួយទៀត ។ រំពេចនោះ បងស្រី វ៉ាស្កិន ដែលជាគ្រូសួរសុខទុក្ខម្នាក់របស់យើង បានមកដល់មាត់ទ្វារដោយមិនបានរំពឹងទុក ។ ដោយជាម្ដាយនៃកូនធំៗ នោះគាត់ដឹងថាត្រូវធ្វើអ្វីដើម្បីជួយ ។ គាត់បានប្រាប់ខ្ញុំពីអ្វីដែលខ្ញុំត្រូវធ្វើ នៅពេលដែលគាត់ទៅកន្លែងលក់ថ្នាំ ។ ក្រោយមក គាត់បានរៀបចំដើម្បីឲ្យគេទៅទទួលស្វាមីខ្ញុំពីស្ថានីយរថភ្លើង ដើម្បីស្វាមីខ្ញុំអាចឆាប់មកដល់ផ្ទះដើម្បីជួយខ្ញុំ ។ ខ្ញុំជឿថា ការឆ្លើយតបរបស់គាត់បានទទួលការបំផុសពីព្រះវិញ្ញាណបរិសុទ្ធ បូករួមនឹងឆន្ទៈរបស់គាត់ក្នុងការបម្រើខ្ញុំ គឺជាការអះអាងដែលខ្ញុំត្រូវការពីព្រះអម្ចាស់ ថាទ្រង់នឹងជួយខ្ញុំដើម្បីបំពេញការហៅបម្រើថ្មីរបស់ខ្ញុំ » ។

ព្រះវរបិតាសួគ៌ស្រឡាញ់យើង ហើយជ្រាបពីស្ថានភាព និងសមត្ថភាពរបស់យើង ។ ទោះជាយើងស្វែងរកជំនួយពីទ្រង់ប្រចាំថ្ងៃតាមរយៈការអធិស្ឋាន តែជាធម្មតា គឺតាមរយៈមនុស្សផ្សេងទៀតដែលទ្រង់ឆ្លើយតបតម្រូវការរបស់យើង ។

ព្រះអម្ចាស់បានមានបន្ទូលថា « គេនឹងដឹងថា អ្នករាល់គ្នាជាសិស្សរបស់ខ្ញុំ ដោយសារសេចក្ដីនេះឯង គឺដោយអ្នករាល់គ្នាមានសេចក្ដីស្រឡាញ់ដល់គ្នាទៅវិញទៅមក » ។[7]

សេចក្ដីស្រឡាញ់ដ៏សុទ្ធសាធនៃព្រះគ្រីស្ទត្រូវបានបង្ហាញ នៅពេលយើងបម្រើដោយគ្មានភាពអាត្មានិយម ។ ការជួយគ្នាទៅវិញទៅមកគឺជាបទពិសោធន៍ដ៏សក្ដិសិទ្ធិ ដែលលើកតម្កើងអ្នកដែលទទួល និងធ្វើឲ្យអ្នកផ្ដល់មានការបន្ទាបខ្លួន ។ វាជួយយើងឲ្យក្លាយជាសិស្សដ៏ពិតនៃព្រះគ្រីស្ទ ។

ផែនការសុខុមាលភាពតែងតែជាការអនុវត្តន៍គោលការណ៍ដ៏អស់កល្បនៃដំណឹងល្អ ។ វាពិតជាផ្ដល់ឲ្យក្នុងរបៀបរបស់ព្រះ ។ ចូរយើងម្នាក់ៗរំលឹកនូវសេចក្ដីប្រាថ្នារបស់យើងក្នុងការធ្វើជាផ្នែកនៃឃ្លាំងរបស់ព្រះអម្ចាស់ នៅក្នុងការផ្ដល់ពរជ័យដល់អ្នកដទៃទៀត ។

ខ្ញុំអធិស្ឋានថា ព្រះអម្ចាស់នឹងប្រទានពរដល់យើងម្នាក់ៗ ជាមួយនឹងក្ដីមេត្តាករុណា សប្បុរស និងក្ដីអាណិតអាសូរ ។ ខ្ញុំសូមអង្វរដើម្បីសេចក្ដីប្រាថ្នា និងសមត្ថភាពរបស់យើងបានកើនឡើង ដើម្បីឈោងទៅជួយអ្នកដែលអភ័ព្វ មានទុក្ខព្រួយ និងរងទុក្ខ ដើម្បីឲ្យតម្រូវការរបស់គេត្រូវបានឆ្លើយតប ដើម្បីជំនឿរបស់គេត្រូវបានពង្រឹងឡើង និងដួងចិត្តរបស់គេត្រូវបានបំពេញដោយការដឹងគុណ និងក្ដីស្រឡាញ់ ។

សូមព្រះអម្ចាស់ប្រទានពរយើងម្នាក់ៗ កាលយើងដើរក្នុងការគោរពបញ្ញត្ត ដំណឹងល្អ និងពន្លឺរបស់ទ្រង់ ។ ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. សូមមើល ម៉ូសេ 7:18 ។
2. សូមមើល ម៉ាថាយ 22:36–40 ។
3. គោលលទ្ធិ និងសេចក្ដីសញ្ញា 44:6 ។
4. *History of the Church* 4:567 ។
5. Minutes of the Female Relief Society of Nauvoo ខែ មិនា ឆ្នាំ 1842 ទំព័រ 7 ។
6. *Providing in the Lord's Way: A Leader's Guide to Welfare* ។
7. យ៉ូហាន 13:35 ។